ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៦៤/១១-ហ្គូដ ភីភីល
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១២

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ ក្រុមហ៊ុន **ហ្គូដ ភីភីល (ខេមបូឌា) អិលធីឌី**

អាសយដ្ឋាន ៖ ភូមិត្រពាំងល្វា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩២ ២១១ ១៧២ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ ៖

| | |
|---|---|
| ១- លោក អ៊ុត សុផាណារិទ្ធិ | ប្រធានរដ្ឋបាល |
| ២- លោក Mun Hee Chul | អ្នកបកប្រែ |
| ៣- លោក ជាតិ ខេមរ៉ា | មន្ត្រី GMAC |

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី២ ៖

| | |
|---|---|
| ១- លោក Kang Mun Won | ប្រធានរោងចក្រ |
| ២- លោក អ៊ុត សុផាណារិទ្ធិ | ប្រធានរដ្ឋបាល |
| ៣- លោក Moon | អ្នកបកប្រែ |
| ៤- លោក ជាតិ ខេមរ៉ា | មន្ត្រី GMAC |



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥ ២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

៥- លោក Piseth ប្រតិភូបុគ្គលិក

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **សហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា**

អាសយដ្ឋាន ៖ ផ្ទះលេខ ១៧ E1 ផ្លូវ ២០០៤ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៦៣៦ ៧៦៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១ ៖

| | | |
|---|---|---|
| ១- | លោក ស្រៀង ណារិទ្ធិ | អនុប្រធានសហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា |
| ២- | កញ្ញា ឈឹម ស្រីមាន | តំណាងកម្មករ |
| ៣- | កញ្ញា ប៉ុន ម៉ៃ | តំណាងកម្មករ |
| ៤- | កញ្ញា គិត ចាន់រតនា | តំណាងកម្មករ |

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី២ ៖

| | | |
|---|---|---|
| ១- | លោក ស្រៀង ណារិទ្ធិ | អនុប្រធានសហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា |
| ២- | កញ្ញា ឈឹម ស្រីមាន | តំណាងកម្មករ |
| ៣- | កញ្ញា ប៉ុន ម៉ៃ | តំណាងកម្មករ |
| ៤- | កញ្ញា វង្ស ឡាង | តំណាងកម្មករ |
| ៥- | កញ្ញា សោម ដាវី | តំណាងកម្មករ |
| ៦- | លោក ចាន់ សារ៉េត | អនុប្រធានសមាគម CAMDA |
| ៧- | កញ្ញា ស៊ុំ សុខឃឿន | តំណាងកម្មករ |
| ៨- | កញ្ញា អិត សុផល | តំណាងកម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ចំពោះកម្មករនិយោជិតដែលធ្វើការលើសពីពីរខែឡើងទៅ សុំបញ្ចូលជាកម្មករពេញសិទ្ធិ ។

២- សុំឱ្យក្រុមហ៊ុនទទួលយកកម្មករនិយោជិតឈ្មោះ សុក រ៉ន, វង់ ឡាង, អ៊ិត សុផល, ស៊ុំ សុខខឿន, អាត និមល, សោម ដាវី, គិត ចាន់រតនី, ឈឹម ស្រីមាន, ផន ម៉ៃ, វ៉ា ណៃយ៉េ ដែលក្រុមហ៊ុនបានបញ្ឈប់ដោយគ្មានមូលហេតុសមរម្យកាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ឱ្យចូលធ្វើការជាធម្មតាវិញ ។

៣- សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យស្ត្រីមានផ្ទៃពោះបានទៅពិនិត្យសុខភាពមួយថ្ងៃក្នុងមួយខែ ដោយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗឱ្យនៅដដែល ។

THE ARBITRATION COUNCIL

៤- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ជំនាញចំពោះកម្មករដែលមានជំនាញចាប់ពីម៉ាស៊ីនមួលមួយចំនួនបីដុល្លា ជំនាញម៉ាស៊ីនមួលពីរចំនួនប្រាំមួយដុល្លា ជំនាញម៉ាស៊ីនមួលបីចំនួនដប់ដុល្លា និងជំនាញម៉ាស៊ីនមួលបួនឡើងទៅចំនួនដប់ប្រាំដុល្លាក្នុងមួយខែ ។

៥- ក្រុមហ៊ុនមិនត្រូវប្រើកម្មករដែលមានជំនាញទៅធ្វើអនាម័យតាមក្រុមទេ ។

៦- ក្រុមហ៊ុនត្រូវរៀបចំពិនិត្យសុខភាពជូនកម្មករមួយឆ្នាំម្តង ហើយក្រុមហ៊ុនត្រូវទទួលខុសត្រូវលើការចំណាយនេះ ។

៧- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួនដប់ដុល្លាក្នុងមួយខែ ។

៨- ចំពោះប្រាក់រង្វាន់ធ្វើការទៀងទាត់ នៅពេលកម្មករឈប់សម្រាកក្រុមហ៊ុនមិនត្រូវកាត់ទាំងអស់នោះទេ គឺកាត់ជាសមាមាត្រទៅតាមចំនួនថ្ងៃដែលកម្មករបានឈប់សម្រាក ។

៩- សុំឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលគោលជូនកម្មករនិយោជិតចំនួន ៦៥ ដុល្លា ក្នុងមួយខែ ។

១០- នៅពេលកម្មករនិយោជិតដេរដល់ចំនួនកំណត់ សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន១០ដុល្លារក្នុងមួយខែ ។

១១- នៅពេលកម្មករមានជម្ងឺមានសុះបុត្រពេទ្យរដ្ឋត្រឹមត្រូវ សុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំឱ្យនៅដដែល ។

១២- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃធ្វើដំណើរ និងថ្លៃឈ្នួលផ្ទះជូនកម្មករនិយោជិតចំនួន១៥ដុល្លារក្នុង១ខែ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិក ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៣៥៣ កប/អក/វក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១។

**សវនាការ និង សន្ទេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖

- សវនាការលើកទី១ ៖ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១១ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក )។

- សវនាការលើកទី២ ៖ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១២ (វេលាម៉ោង ២ រសៀល )។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា លេខ ០២៥/១១ សសសក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ឱ្យ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន១២ចំណុច លើការទាមទារចំនួន១២ចំណុច។ ចំណុចមិនសះជាចំនួន ១២ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ១៣៥៣កប/អក/វក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១២ ចំណុចនេះ នៅលើកទី១ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរបានអញ្ជើញមកតាមកាលកំណត់ ប៉ុន្តែនៅថ្ងៃសវនាការភាគីតំណាងនិយោជកបានស្នើរសុំលើកថ្ងៃសវនាការ ព្រោះថា អគ្គនាយកក្រុមហ៊ុនមានបេសកម្មទៅក្រៅប្រទេសរយៈពេលចំនួនមួយសប្តាហ៍។ ហេតុនេះ ភាគីវិវាទក៏បានព្រមព្រៀងគ្នាកំណត់សវនាការជាលើកទី២ គឺនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២ វេលាម៉ោង ២ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ ហើយជាលទ្ធផលភាគីកម្មករនិយោជិតបានយល់ព្រមដកចំណុចទាមទារចំនួន ១១ ចំណុច ដែលមានដូចជាចំណុចវិវាទទី១ ទី៣ ទី៤ ទី៥ ទី៦ ទី៧ ទី៨ ទី៩ ទី១០ ទី១១ និងទី១២។ ដូចនេះ ចំណុចវិវាទ ដែលត្រូវពិចារណា គឺមានតែមួយចំណុចប៉ុណ្ណោះ គឺចំណុចវិវាទទី២។

ក្នុងសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការភាគីនិយោជក និងកម្មករនិយោជិត បានយល់ព្រមពន្យាថ្ងៃចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០១១ ទៅដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១២។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតរបស់ក្រុមហ៊ុន ហ្គូដ ភីភីល លេខ HR-Admin 072-12/2011 GP-C គោរពជូនប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីសំណើសុំលើកពេលវេលាចូលរួមធ្វើសវនាការ (សំណុំរឿងលេខ ១៦៤/១១) ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ។

២- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ក្រុមហ៊ុន ហ្គូដ ភីភីល ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ។

៣- ប័ណ្ណប៉ាតង់ឆ្នាំ២០១១ ក្រុមហ៊ុន ហ្គូដ ភីភីល ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ ។

៤- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ហ្គូដ ភីភីល ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០១១ ។

៥- សេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស ក្រុមហ៊ុន ហ្គូដភីភីល ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១ ។

៦- កំណត់ហេតុកិច្ចព្រមព្រៀងស្ដីពីការប្រើប្រាស់កិច្ចសន្យាការងារ ដែលមានថិរវេលាកំណត់ លេខ HR-Admin 004-15/2011 GP-C ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ ។

៧- រូបភាពកិច្ចព្រមព្រៀងស្ដីពីការប្រើប្រាស់កិច្ចសន្យាការងារដែលមានថិរវេលាកំណត់ ។

៨- លក្ខន្តិកៈក្រុមហ៊ុន ហ្គូដ ភីភីល ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១ ។

៩- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ហ្គូដ ភីភីល ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១ ។

១០- អនុសញ្ញារួមស្ដីពីការបើកប្រាក់ឈ្នួល ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ។

១១- លិខិតបំភ្លឺរបស់មេធាវី សៃ គុត្តកូលា ស្ដីពីដំណើរការបញ្ចប់កិច្ចសន្យាសាកល្បងការងារជាមួយកម្មករចំនួន ១១ នាក់ នៃរោងចក្រ ហ្គូដ ភីភីល កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ នៅរោងចក្រ ហ្គូដ ភីភីល ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ។

១២- លិខិតប្រគល់សិទ្ធិរបស់លោក Kang Mun Won ជូនលោកស្រីមេធាវី សៃ គុត្តកូលា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១ ។

១៣- ស្នាមមេដៃរបស់បុគ្គលិក និងជាប្រធានក្រុម ប្រធានផ្នែកនៃក្រុមហ៊ុន Good People ធ្វើការវាយតំលៃ និងវិនិច្ឆ័យទៅលើការងាររបស់កម្មករនិយោជិតចំនួន១១រូប ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ។

១៤- លិខិតរបស់នាយកក្រុមហ៊ុន ហ្គូដ ភីភីល លេខ Admin-HR.021 ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ជូនលោកប្រធាននាយកដ្ឋានវិវាទ ការងារនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ស្ដីពីការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតធ្វើការងារសាកល្បង ដែលក្រុមហ៊ុនមិនបន្តកិច្ចសន្យាការងារ ។

១៥- សេចក្ដីជូនដំណឹងរបស់ក្រុមហ៊ុន ហ្គូដ ភីភីល លេខ Admin-HR.GP-C005-15.2011 ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ស្ដីពីការមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន៨រូប ។

១៦- សេចក្ដីជូនដំណឹងរបស់ក្រុមហ៊ុន ហ្គូដ ភីភីល លេខ Admin-HR.GP-C006-15.2011 ចុះថ្ងៃទី១៥

ខែតុលា ឆ្នាំ២០១១ ឱ្យកម្មករនិយោជិតដែលធ្វើការសាកល្បង ហើយបោះបង់ការងារ មកបើកប្រាក់ឈ្នួល ។

១៧- វិក្កយប័ត្រប្រាក់ខែរបស់ឈ្មោះ គិត ចាន់រត្ថានី ។

១៨- វិក្កយប័ត្រប្រាក់ខែរបស់ឈ្មោះ សុខ រ៉ន ។

១៩- កិច្ចសន្យាការងារ (សំរាប់កម្មករសាកល្បង) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង សោម ដានី ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ។

២០- កិច្ចសន្យាការងារ (សំរាប់កម្មករសាកល្បង) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង សុំ សុខឿន ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

២១- កិច្ចសន្យាការងារ (សំរាប់កម្មករសាកល្បង) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង ប៉ុន ម៉ៃ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ។

២២- កិច្ចសន្យាការងារ (សំរាប់កម្មករសាកល្បង) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង អ៊ុត សុផល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

២៣- កិច្ចសន្យាការងារ (សំរាប់កម្មករសាកល្បង) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង វ៉ង់ ឡាំង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

២៤- កិច្ចសន្យាការងារ (សំរាប់កម្មករសាកល្បង) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង សុខ រ៉ន ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

២៥- កិច្ចសន្យាស្តីពីការមិនប្តឹងតវ៉ារបស់ឈ្មោះ សុខ រ៉ន ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ ។

២៦- កិច្ចសន្យាការងារ (សំរាប់កម្មករសាកល្បង) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង ឈឹម ស្រីមាន ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

២៧- កិច្ចសន្យាការងារ (សំរាប់កម្មករសាកល្បង) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង អាត និមល ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ។

២៨- កិច្ចសន្យាការងារ (សំរាប់កម្មករសាកល្បង) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង គិត ចាន់រតនី ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

២៩- កិច្ចសន្យាស្តីពីការមិនប្តឹងតវ៉ារបស់ឈ្មោះ គិត ចាន់រត្ថានី ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ។

៣០- កិច្ចសន្យាការងារ (សំរាប់កម្មករសាកល្បង) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង ណេង វណ្ណារ៉េត ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

៣១- កិច្ចសន្យាការងារ (សំរាប់កម្មករសាកល្បង) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង យិន សោភា ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

៣២- កិច្ចសន្យាការងារមានថិរវេលាកំណត់សំរាប់ (កម្មករ កម្មការិនី) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង យន់ សោភា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ ។

៣៣- លិខិតសុំលាឈប់ពីការងារឈ្មោះ យុន សោភា ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ។

៣៤- កិច្ចសន្យាការងារ (សំរាប់កម្មករសាកល្បង) រវាងក្រុមហ៊ុន ហ្គូដ ភីភីល និង វ៉ា ណាយ៉េក ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១១ ។

៣៥- លិខិតរបស់ក្រុមហ៊ុន ហ្គូដ ភីភល លេខ HR-Admin 072/Jan2012 ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ ស្តីពីការបដិសេធខ្លឹមសារ សារណាសង្ខេបនៃវិវាទការងារ ។

៣៦- លិខិតបំភ្លឺរបស់ ឈឹម សុធារី ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតរបស់សហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា លេខ ០២៩/១២ សសសក ស្តីពីការជំទាស់ឯកសាររបស់ក្រុមហ៊ុន ហ្គូដ ភីភីល ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ ។

២- សារណាសង្ខេបស្តីពីវិវាទនៃរោងចក្រ ហ្គូដ ភីភីល ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១២ ។

៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ហ្គូដ ភីភីល ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៤- លិខិតបដិសេធរបស់ សុខ រ៉ន ចុះខែមករា ឆ្នាំ២០១២ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្គូដ ភីភីល លេខ ១៣៥៣ កប/អក/វក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ហ្គូដ ភីភីល ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី១ លេខ ៩១១ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១១ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ លេខ ៩១២ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ២០១១ ។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ៩៣៤ កប/អក/វក/លកអ. ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១១ ។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៩៣៥ កប/អក/វក/លកអ. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ។

THE ARBITRATION COUNCIL

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្ដាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ៖

- ក្រុមហ៊ុន ហ្គូដ ភីភីល (ខេមបូឌា) អិលធីឌី បានបើកដំណើរការនៅខែមិថុនា ឆ្នាំ២០១១ គឺជាក្រុមហ៊ុនកាត់ដេរសំលៀបំពាក់ (សំលៀកបំពាក់ក្នុង)។ បច្ចុប្បន្នក្រុមហ៊ុនមានជួលកម្មករនិយោជិតសរុបមានចំនួន ៣៦០ នាក់។
- នៅក្នុងក្រុមហ៊ុននេះ ពុំទាន់មានសហជីពនៅឡើយទេ។
- មានកម្មការិនីចំនួន ៦ នាក់ ដែលជាដើមបណ្ដឹងនៅក្នុងសំណុំរឿងនេះ។ ពួកគាត់ទាំង ៦ នាក់ត្រូវបានអមដោយមន្ត្រីសហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា និងមន្ត្រីអនុប្រធានសមាគម CAMDA នៅថ្ងៃសវនាការ។

**ចំណុចវិវាទទី ២ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករ ឈ្មោះ សុក រ៉ន, វង្ស ឡាង, អ៊ិត សុផល, ស៊ុំ សុខឃឿន, អាត និមល, សោម ដាវី, គិត ចាន់រតនី, ឈឹម ស្រីមាន, ប៉ុន ម៉ៃ និង វ៉ា ណៃយ៉េ ដែលក្រុមហ៊ុនបានបញ្ឈប់ដោយគ្មានមូលហេតុសមរម្យ កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ឱ្យចូលធ្វើការងារវិញ**

- តាមរយៈរបាយការណ៍មិនសះជារបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មានកម្មការិនីចំនួន ១០ នាក់ ទាមទារឱ្យនិយោជកទទួលយកចូលធ្វើការងារវិញ។ ប៉ុន្តែ នៅថ្ងៃសវនាការមានតែកម្មការិនីចំនួន ៦ នាក់ ដែលមានវត្តមានក្នុងការទាមទារនេះ ដែលមានឈ្មោះ ឈឹម ស្រីមាន, ប៉ុន ម៉ៃ, វង្ស ឡាង, សោម ដាវី, ស៊ុំ សុខឃឿន និង អិត សុផល។ ចំណែកឯកម្មការិនី ដែលមានឈ្មោះ សុក រ៉ន, គិត ចាន់រតនី , អាត និមល និង វ៉ា ណៃយ៉េ មិនមានវត្តមានក្នុងសវនាការទេ ហើយក៏ពុំបានធ្វើលិខិតផ្ទេរសិទ្ធិជូនអ្នកណាម្នាក់ឱ្យជំនួស ដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីទាមទារដែរ។
- ក្នុងចំណោមកម្មការិនីទាំង ៦ នាក់ខាងលើ មានខ្លះចូលធ្វើការងារដំបូង នៅថ្ងៃទី១៧ និងខ្លះទៀត នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ដោយពុំមានចុះកិច្ចសន្យាការងារលាយលក្ខណ៍អក្សរទេ គ្រាន់តែឆ្លងកាត់ការដាក់ពាក្យសុំចូលធ្វើការ និងការសម្ភាសន៍ជាប់ ហើយនិយោជកឱ្យចូលធ្វើការ។ ក្រោយជាប់ឱ្យចូលធ្វើការដំបូង ក្រុមហ៊ុនបានបង្រៀនភាសាកូរ៉េសម្រាប់ទំនាក់ទំនងប្រចាំថ្ងៃ និងបណ្ដុះបណ្ដាលជំនាញបន្ថែមដល់ពួកគាត់ ដោយហេតុថា ពួកគាត់មានជំនាញហើយមែន តែក្រុមហ៊ុននេះដេរខោអាវក្នុង ដូច្នេះការដេរ គឺខុសគ្នាពីខោអាវពាក់ខាងក្រៅធម្មតា ហើយកម្មករម្នាក់ៗត្រូវធ្វើច្រើនមុខ ដូចជាការដេរម្ជុល១ ឬដេរម្ជុលពីរជាដើម ដោយមិនទាន់រៀបចំឱ្យពួកគាត់ធ្វើការនៅក្នុងសង្វាក់ផលិតកម្មនៅឡើយទេ។ នៅពេលនោះ ក្រុមហ៊ុននឹងពិនិត្យមើលថា តើកម្មករនិយោជិតរូបណាមានជំនាញណាច្បាស់លាស់ ទើបដាក់កម្មករ

និយោជិតនោះទៅក្នុងសង្វាក់ផលិតកម្ម។ រយៈពេលធ្វើការនោះ ពួកគាត់ទទួលបានប្រាក់ឈ្នួលចំនួន ៦១ ដុល្លារអាមេរិកក្នុងមួយខែ ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ។

- រយៈពេលប្រហែល ៣ ខែ ក្រោយមក និយោជក និងកម្មករនិយោជិតបានចុះកិច្ចសន្យាការងារសាកល្បងដូចខាងក្រោម ៖
  - ឈឹម ស្រីមាន ៖ កិច្ចសន្យាការងារសាកល្បងរយៈពេល២ខែ គិតចាប់ពី ថ្ងៃទី១៨ ខែសីហា រហូតដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១។
  - ប៊ុន ម៉ៃ ៖ កិច្ចសន្យាការងារសាកល្បងរយៈពេល២ខែ គិតចាប់ពីថ្ងៃទី១៧ ខែសីហា រហូតដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១១។
  - វង្ស ឡាង ៖ កិច្ចសន្យាការងារសាកល្បងរយៈពេល២ខែ គិតចាប់ពីថ្ងៃទី១៨ ខែសីហា រហូតដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១។
  - សោម ដាវី ៖ កិច្ចសន្យាការងារសាកល្បងរយៈពេល២ខែ គិតចាប់ពីថ្ងៃទី១៧ ខែសីហា រហូតដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១១។
  - ស៊ុំ សុខឃឿន ៖ កិច្ចសន្យាការងារសាកល្បងរយៈពេល២ខែ គិតចាប់ពីថ្ងៃទី១៨ ខែសីហា រហូតដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១។
  - អិត សុផល ៖ កិច្ចសន្យាការងារសាកល្បងរយៈពេល ២ ខែ គិតចាប់ពី ថ្ងៃទី១៨ ខែសីហា រហូតដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១។
- នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ក្រុមហ៊ុនបានបញ្ចប់កិច្ចសន្យាការងារសាកល្បងពួកគាត់ទាំង ៦ នាក់ ដោយជូនដំណឹងនៅថ្ងៃបញ្ចប់នោះតែម្តង។
- នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១ កម្មករនិយោជិតបានធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់រង្វាន់ធ្វើការទៀងទាត់បន្ថែមចំនួន ៣ ដុល្លារអាមេរិក និងតម្លើងប្រាក់ឈ្នួលចំនួន ៤ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។
- នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១១ វេលាថ្ងៃត្រង់ តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះដោះស្រាយនៅក្រុមហ៊ុន។ ប៉ុន្តែ ក្រុមហ៊ុនមិនព្រមជួបដោះស្រាយទេ។ ហេតុនេះ ក្រសួងបានចេញលិខិតអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតទៅដោះស្រាយនៅក្រសួងការងារ នៅវេលាម៉ោង ១៤ និង ០០ នាទី រសៀល ក្នុងថ្ងៃដដែល។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា នៅពេលនោះ ភាគីក្រុមហ៊ុនស្នើសុំដោះស្រាយជាមួយកម្មករនិយោជិតផ្ទាល់ មិនដោះស្រាយជាមួយសហជីពទេ។ ហេតុនេះ កម្មករនិយោជិតបានចាត់តាំងឱ្យពួកគាត់ (ទាំង១០នាក់ ដែលក្រុមហ៊ុនបានបញ្ឈប់) ជាតំណាងធ្វើការដោះស្រាយនៅក្រសួង។ ប៉ុន្តែមិនទទួលបានលទ្ធផលទេ។
- បន្ទាប់មក កម្មករនិយោជិតបានធ្វើកូដកម្មបន្តទៀត រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ៩ និង ០០ នាទី ព្រឹក ភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតបានដោះស្រាយដោយមានកិច្ចព្រមព្រៀង

គ្នាមួយ ហើយកម្មករនិយោជិតបានចូលធ្វើការវិញ (ដូចមានកិច្ចព្រមព្រៀងចុះថ្ងៃទី១១ ខែតុលា ឆ្នាំ ២០១១ ដែលបានផ្តល់ជូនដោយភាគី)។

- ភាគីនិយោជកបានលើកឡើងថា មូលហេតុដែលបញ្ចប់កិច្ចសន្យាការងាររបស់ពួកគាត់ គឺដោយសារតែកិច្ចសន្យាការងារសាកល្បងរយៈពេល២ខែ របស់ពួកគាត់ត្រូវដល់កាលកំណត់ ដូចនេះ និយោជកពុំចាំបាច់គោរពកាតព្វកិច្ចជូនដំណឹងមុននោះទេ ហើយនិយោជកក៏ពុំចាំបាច់ផ្តល់ហេតុផលក្នុងការបញ្ចប់ទៅពួកគាត់ដែរ។ ម្យ៉ាងទៀត ពួកគាត់ធ្វើការមិនសូវល្អ មិនយកចិត្តទុកដាក់នឹងការងារ និងនិយាយគ្នាច្រើន ដែលជាហេតុធ្វើឱ្យនិយោជកមិនអាចបន្តកិច្ចសន្យាជាមួយពួកគាត់តទៅទៀត។
- ភាគីនិយោជកបានបញ្ជាក់ផងដែរថា ចំពោះកម្មករនិយោជិតដែលបានធ្វើការងារចំនួនប្រហែលជា ៣ ខែ មុនពេលចុះកិច្ចសន្យាការងារសាកល្បងនោះ គឺជាការបណ្តុះបណ្តាលឱ្យស្គាល់ការងារ ដោយពុំមានធ្វើជាលាយលក្ខណ៍អក្សរទេ។
- ភាគីកម្មករនិយោជិតបានលើកឡើងថា កិច្ចសន្យាការងារសាកល្បងពួកគាត់ត្រូវចប់នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ ប៉ុន្តែនិយោជកបានបញ្ចប់ពួកគាត់នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ដូចនេះនិយោជកបានបញ្ឈប់ពួកគាត់មុនកិច្ចសន្យាដល់កាលកំណត់ទៅទៀត។ នេះមានន័យថា និយោជកមានការរើសអើង និងគុំគួនពួកគាត់ ដោយសារតែពួកគាត់ធ្លាប់បានតំណាងឱ្យកម្មករនិយោជិតនៅក្នុងរោងចក្រ ដើម្បីធ្វើការចរចារទាក់ទងទៅនឹងបញ្ហាកូដកម្មកន្លងមកនោះ (ពីថ្ងៃទី០៦ ដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១) លើការទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់រង្វាន់ធ្វើការទៀងទាត់បន្ថែមចំនួន ៣ ដុល្លារអាមេរិក និងតំឡើងប្រាក់ឈ្នួលចំនួន៤ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។ ទន្ទឹមនឹងនេះដែរ កន្លងមក ពួកគាត់ពុំដែលប្រព្រឹត្តកំហុសធ្ងន់ ឬកំហុសណាមួយទេ តួយ៉ាងដូចជាមុននឹងចុះកិច្ចសន្យាការងារសាកល្បង ពួកគាត់បានធ្វើការល្អជូននិយោជកចំនួនប្រហែល ៣ ខែ កន្លងមកហើយ។
- ភាគីកម្មករនិយោជិតអះអាងថា ពួកគាត់ជាតំណាងកម្មករនិយោជិត ដែលកម្មករនិយោជិតបានចាត់តាំងឱ្យ ហើយក្រុមហ៊ុនបញ្ឈប់ ដោយគ្មានមូលហេតុសមរម្យ។ ហេតុនេះ ពួកគាត់នៅតែទាមទារឱ្យក្រុមហ៊ុនទទួលយកចូលធ្វើការវិញ។
- ភាគីក្រុមហ៊ុនរក្សាជំហរមិនអាចទទួលយកពួកគាត់ឱ្យចូលធ្វើការវិញតាមការទារទាមបានទេ។

**ហេតុផលនៃសេចក្តីសម្រេច**

**ចំណុចវិវាទទី ២ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករ ឈ្មោះ សុក រ៉ន, វង្ស ឡាង, អ៊ិត សុផល, ស៊ុំ សុខឃឿន, អាត និមល, សោម ដាវី, គិត ចាន់រតនី, ឈឹម ស្រីមាន, ប៉ុន រ៉េម និង រ៉ា ណៃយ៉េ ដែលក្រុមហ៊ុនបានបញ្ឈប់ដោយគ្មានមូលហេតុសមរម្យ កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ឱ្យចូលធ្វើការងារវិញ**

តាមរយៈរបាយការណ៍មិនសះជាពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកម្មករនិយោជិតចំនួន ១០ នាក់ ដែលបានទាមទារនៅក្នុងសំណុំរឿងនេះ។ ប៉ុន្តែ នៅថ្ងៃសវនាការ មានកម្មករនិយោជិតចំនួន ៦ នាក់

ប៉ុណ្ណោះ ដែលមានវត្តមាន គឺកម្មករ ដែលមានឈ្មោះ ឈឹម ស្រីមាន, ប៊ុន ម៉ៃ, វង្ស ឡាង, សោម ដាវី, ស៊ុំ សុខឃឿន និង អិត សុផល ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាទៅលើចំនួនដើមបណ្តឹង ដូចតទៅ ៖

ប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួនទៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម...ឬដោយបុគ្គលផ្សេងទៀត ដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"* ។

យោងតាមប្រការ ១៩ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យថា *"ទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ"* មានន័យថា ភាគីវិវាទអាចឱ្យបុគ្គលផ្សេង តំណាងឱ្យខ្លួនក្នុងការដោះស្រាយវិវាទការងារនៅចំពោះមុខក្រុមអាជ្ញាកណ្តាលបាន លុះត្រាតែបុគ្គលនោះ ទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដើម្បីមកធ្វើជាតំណាងរបស់ភាគីវិវាទ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៤០/១១- ក្លូប៊ល អាប៉ារ៉ែល ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២) ។

តាមរយៈអង្គហេតុ មានកម្មការិនីចំនួន ៦ នាក់ ដែលមានឈ្មោះ ឈឹម ស្រីមាន, ប៊ុន ម៉ៃ, វង្ស ឡាង, សោម ដាវី, ស៊ុំ សុខឃឿន និង អិត សុផល ដែលជាដើមបណ្តឹង បានមកបង្ហាញខ្លួននៅសវនាការ ដើម្បីបញ្ជាក់ពីការទាមទាររបស់ខ្លួន។ ចំណែកឯកម្មការិនីចំនួន ៤ នាក់ផ្សេងទៀត ដែលមានឈ្មោះដូចជា សុក វ៉ន, គិត ចាន់រតនី, អាត និមល និង វ៉ា ណៃយ៉េ ពុំបានមកបង្ហាញខ្លួននៅក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ហើយពួកគាត់ទាំង ៤ នាក់ ក៏មិនបានបង្ហាញលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរណាមួយមកក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចពិចារណាតែកម្មការិនីចំនួន ៦នាក់ ដែលបានមកសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាលប៉ុណ្ណោះ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកត្រូវទទួលយកកម្មការិនីទាំង ៦ នាក់ ឱ្យចូលធ្វើការងារវិញដែរ ឬទេ?

ភាគីនិយោជកបានលើកឡើងថា ករណីបញ្ចប់កិច្ចសន្យាកម្មការិនីខាងលើ គឺដោយសារតែកិច្ចសន្យាការងារសាកល្បងរយៈពេល ២ ខែ របស់ពួកគាត់ ត្រូវដល់កាលកំណត់។ ចំណែកឯរយៈពេល ៣ ខែ ដែលកម្មារិនីបានធ្វើការមុនពេលកិច្ចសន្យាការងារសាកល្បងនោះ គឺជាការបណ្តុះបណ្តាលឱ្យស្គាល់ការងារ ដោយកម្មករនិយោជិតត្រូវធ្វើការច្រើនមុខ និងបង្រៀនជំនាញបច្ចេកទេស ដូចជា ម្ជុលមួយ ម្ជុលពីរ ជាដើម ពីព្រោះក្រុមហ៊ុនដេរខោក្នុង ដែលទាមទារនូវជំនាញច្បាស់លាស់ និងបង្រៀនភាសារកូរ៉េ សម្រាប់ធ្វើការទំនាក់ទំនងប្រចាំថ្ងៃ ដោយមិនទាន់រៀបចំឱ្យពួកគាត់ធ្វើការនៅក្នុងសង្វាក់ផលិតកម្មជាក់លាក់ណាមួយទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកអាចធ្វើការបណ្តុះបណ្តាល និងបង្រៀនជំនាញផ្សេងៗ ដល់កម្មករនិយោជិតរបស់ខ្លួនសម្រាប់រយៈពេលប្រមាណ ៣ ខែ មុននឹងចុះកិច្ចសន្យាការងារសាកល្បង ដែរ ឬ ទេ?

យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទំនាក់ទំនងការងាររវាងក្រុមហ៊ុន និងកម្មករនិយោជិត (ទំនាក់ទំនងកម្មករនិយោជិត និងនិយោជក) បានចាប់ផ្តើមរួចហើយដោយផ្ទាល់មាត់ គ្រាន់តែមិនមានកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ ហើយភាគីក៏បានយល់ដឹងពីលក្ខណ្ឌការងាររួចហើយដែរ ។

មាត្រា ៦៨ នៃច្បាប់ស្តីពីការងារចែងថា “*ការចុះកិច្ចសន្យាសាកល្បង មិនអាចមានថិរវេលាលើសកាលបរិច្ឆេទជាចាំបាច់ សម្រាប់ឱ្យនិយោជកវិនិច្ឆ័យវិជ្ជាជីវៈនៃកម្មករនិយោជិត ហើយនិងសម្រាប់កម្មករនិយោជិតស្គាល់យ៉ាងជាក់ច្បាស់នូវលក្ខខណ្ឌនៃការងារ ដែលគេផ្តល់ឱ្យនោះឡើយ ។ ទោះបីយ៉ាងណាក៏ដោយ ក៏ការចុះកិច្ចសន្យាសាកល្បងការងារមិនអាចមានថិរវេលាលើសពីបីខែទេចំពោះនិយោជិត ពីរខែចំពោះកម្មករឯកទេស និងមួយខែចំពោះកម្មករធម្មតា*” ។

យោងតាមមាត្រានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញមាត្រានេះ ប្បញ្ញត្តិអំពីថិរវេលាអតិបរមា និងគោលបំណងក្នុងការសាកល្បងការងារ ប៉ុន្តែមិនបានកំណត់ថា ពេលណាភាគីទាំងពីរត្រូវចុះកិច្ចសន្យា ឬសាកល្បងការងារជាមួយគ្នានោះទេ ។ ជាទូទៅ យើងសង្កេតឃើញថា ការសាកល្បងការងារធ្វើឡើងនៅពេលចាប់ផ្តើមភ្ជាប់ទំនាក់ទំនងពីដំបូង។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានប្បញ្ញត្តិច្បាប់ណាមួយ ជាពិសេសច្បាប់ស្តីពីការងារដែលចែងហាមឃាត់និយោជកក្នុងការបណ្តុះបណ្តាល និងបង្រៀនជំនាញផ្សេងៗ ដល់កម្មករនិយោជិតរបស់ខ្លួន មុននឹងចុះកិច្ចសន្យាការងារសាកល្បងនោះទេ។ នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតបញ្ជាក់ថា ពួកគាត់បានដឹង និងបានយល់ព្រម ក្នុងការបណ្តុះបណ្តាលភាសា និងរៀនជំនាញផ្សេងៗ និងបានយល់ព្រមចុះកិច្ចសន្យាការងារសាកល្បងរយៈពេល ២ ខែ ផងដែរ។ ចំណែកឯការទាមទារឱ្យនិយោជកទទួលយកពួកគាត់ចូលធ្វើការវិញ ពីព្រោះក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារសាកល្បងរបស់ពួកគាត់ ដោយគ្មានមូលហេតុ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារសាកល្បងរយៈពេល ២ខែ របស់ពួកគាត់ទាំង ៦នាក់នេះ ត្រឹមត្រូវតាមច្បាប់ស្តីពីការដែរ ឬ ទេ?

មាត្រា ៨២ នៃច្បាប់ស្តីពីការងារចែងថា “*ភាគីទាំងឡាយ មិនចាំបាច់គោរពកាតព្វកិច្ចជូនដំណឹងមុន ក្នុងករណីដូចតទៅ៖*

*១- ក្នុងករណីចូលធ្វើការសាកល្បង ឬកម្មសិក្សាដែលមានចែងក្នុងកិច្ចសន្យា....*” ។

ក្នុងករណីនេះ កម្មករនិយោជិតទាំង ៦ នាក់ បានចុះកិច្ចសន្យាការងារសាកល្បងរយៈពេល ២ ខែ។ ផ្អែកលើមាត្រា ៨២ ខាងលើ ច្បាប់ស្តីពីការងារ មិនតម្រូវឱ្យនិយោជកគោរពកាតព្វកិច្ចជូនដំណឹងមុនទេ។

ក្រៅពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានប្បញ្ញត្តិច្បាប់ចែង ដែលតម្រូវឱ្យនិយោជកផ្តល់ហេតុផលក្នុងការបញ្ចប់កិច្ចសន្យាការងារសាកល្បងទេ។ (សូមមើលសេចក្តីបង្គាប់លេខ ២៧/០៣-ស្តែនដឺត ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១) ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនទទួលយកកម្មករឈ្មោះ ឈឹម ស្រីមាន, ប៊ុន ម៉ៃ, វង្ស ឡាង, សោម ដាវី, ស៊ុំ សុខឃឿន និង អិត សុផល ឱ្យចូលធ្វើការវិញ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

THE ARBITRATION COUNCIL

## សម្រេច និង បង្គាប់

ចំណុចវិវាទទី២៖ បដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនទទួលយកកម្មករឈ្មោះ ឈឹម ស្រីមាន, ប៉ុន ម៉ៃ, វង្ស ឡាង, សោម ដាវី, ស៊ុំ សុខឃឿន និង អិត សុផល ឱ្យចូលធ្វើការវិញ។

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា៖ ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា៖ ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ប៊ុនឈា**

ហត្ថលេខា៖ ----------------------------------------

THE ARBITRATION COUNCIL